**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ១២៣៧ មស. ៥៥៣

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការដាក់ឱ្យដំណើរការច្រកអេឡិចត្រូនិចដើម្បីទទួលការស្នើសុំទិដ្ឋាការ ឬការសម្រេចក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមុខងារសាធារណៈ

យោងតាមសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ស្ដីពីវិធានការបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូន សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃគ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា ក្រសួងសម្រេចដាក់ឱ្យដំណើរការច្រកអេឡិចត្រូនិចសម្រាប់ទទួល**សំណុំឯកសារមុខការ** ដើម្បីស្នើសុំទិដ្ឋាការ ឬ ការសម្រេចក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមុខងារសាធារណៈ។ ក្នុងន័យនេះ ក្រសួងសូមស្នើកិច្ចសហការតាមជំហានៗ ដូចខាងក្រោម៖

១) សូមស្កែន (Scan) សំណុំឯកសារមុខការ ជា Portable Document Format (PDF) រួចផ្ញើរ Soft Copy មកកាន់ Telegram លេខ 017-898258

២) ដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងសំណុំឯកសាររបស់ក្រសួង ស្ថាប័ន សូមធ្វើការកំណត់ឈ្មោះសំណុំឯកសារ (File Name) ជាទម្រង់ "**ឈ្មោះក្រសួងស្ថាប័នជាអក្សរកាត់-ឆ្នាំខែថ្ងៃ-លេខ-កម្មវត្ថុ**" ដូចខាងក្រោម៖

- អក្សរឡាតាំង ៖ ឈ្មោះក្រសួងស្ថាប័នជាអក្សរកាត់-ឆ្នាំខែថ្ងៃ-លេខ
- អក្សរខ្មែរ ៖ កម្មវត្ថុ

*ឧទាហរណ៍៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ស្នើសុំតែងតាំងលោក ស្អាន ថ្លល់ ជាអនុប្រធាននាយកដ្ឋាន តាមរយៈលិខិតលេខ៩៩៩សក.បល ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០។ ដូច្នេះយើងត្រូវកំណត់ឈ្មោះឯកសារនោះ គឺ "MPWT-20200318-999-តែងតាំងលោកស្អានថ្លល់"*

៣) ក្រសួង ស្ថាប័ន នៅតែមានភារកិច្ចផ្ញើរសំណុំឯកសារជា Hard Copy មកកាន់ក្រសួងមុខងារសាធារណៈដដែល។ ដោយឡែក សំណុំឯកសារដែលបានផ្ញើរជា Soft Copy រួចហើយ សូមមេត្តាបញ្ជាក់នៅលើស្រោមសំបុត្រនូវពាក្យថា "**បានផ្ញើរ Soft Copy**"។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃគ្រប់ក្រសួង ស្ថាប័ន នឹងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះ តាមការគួរ។

ថ្ងៃ ព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh